# វិធីញែកសំរាម និង វិធីចោលសំរាម

នៅក្នុងក្រុងសាកាអ៊ិដេ មានការកំណត់ពីថ្ងៃចោលសំរាម និងកន្លែងចោលសំរាម ទៅតាមទីតាំងដែលអ្នករស់នៅ។

សូមចោលសំរាមនៅថ្ងៃដែលត្រូវបានកំណត់ នៅកន្លែងចោលសំរាមដែលត្រូវបានកំណត់។

ថ្ងៃចោលសំរាមបាន និងកន្លែងចោលសំរាមបាន ខុសៗគ្នាទៅតាមប្រភេទរបស់សំរាម។ អ្នកមិនអាចចោលសំរាមប្រភេទផ្សេងបានទេ។

ចំពោះ “សំរាមដុតបាន” និង “សំរាមដុតមិនបាន” អ្នកត្រូវតែចោលដោយដាក់វាចូលក្នុងថង់ដែលត្រូវបានកំណត់ដែលគេហៅថង់នោះថា “ថង់ប្រមូលដែលគេកំណត់”។

អ្នកអាចទិញ “ថង់ប្រមូលដែលគេកំណត់” បាននៅតាមផ្សារទំនើបឬម៉ាតនៅក្នុងក្រុង។




ថង់ប្រមូលដែលគេកំណត់ក្នុងក្រុងសាកាអ៊ិដេ (សំរាមដុតបាន និង សំរាមដុតមិនបាន)

**「さんあ～る」** កម្មវិធីទូរសព្ទ ដែលអ្នកអាចមើលពីថ្ងៃចោលសំរាម និងវិធីញែកសំរាម

នៅពេលអ្នកមិនដឹងពីវិធីចោលសំរាម សូមប្រើប្រាស់កម្មវិធីទូរសព្ទ「さんあ～る」ដែលអ្នកអាចប្រើបានដោយឥតគិតថ្លៃ។

ដោនឡូតពី App Store

ដោនឡូតពី Google Play

# ប្រភេទសំរាមសំខាន់ៗ និង វិធីចោល

## ○ សំរាមដុតបាន

របស់សំខាន់ៗ…សំរាមសរីរាង្គ ដូចជាសំណល់បន្លែ សំបកស៊ុត ប្រេងខ្លាញ់ធ្វើម្ហូប ជាដើម

ព្រមទាំងក្រដាស ខោអាវ កម្ទេចឈើ និងដុំស្នោ ជាដើម

ថ្ងៃចោលបាន…ថ្ងៃ “សំរាមដុតបាន” (2ថ្ងៃក្នុងមួយសប្តាហ៍)

វិធីចោល…សូមដាក់វាចូលក្នុង “ថង់ប្រមូលដែលគេកំណត់” ហើយចោលវា

នៅថ្ងៃ “សំរាមដុតបាន” នៅកន្លែងចោលសំរាមដែលត្រូវបានកំណត់

អ្វីដែលត្រូវប្រុងប្រយ័ត្ននៅពេលចោល៖

- ចំពោះសំរាមសរីរាង្គ សូមយកទឹកចេញ ហើយទុកឲ្យស្ងួតល្អ
- សូមចងមាត់ថង់ ដើម្បីកុំឲ្យសំរាមខាងក្នុងចេញមកខាងក្រៅ
- សូមកុំដាក់ “សំរាមដុតបាន” និង “សំរាមដុតមិនបាន” ចូលក្នុងថង់តែមួយឲ្យសោះ
- ចំពោះប្រេងខ្លាញ់ធ្វើម្ហូប សូមជ្រលក់ក្រដាសឬក្រណាត់ចូល ឬ ធ្វើឲ្យវារឹងដោយប្រើសារធាតុបង្កក






## ○ សំរាមដុតមិនបាន

របស់សំខាន់ៗ…ពពួកលោហៈ ដូចជាឆ្នាំង ខ្ទះ កន្ត្រៃ ជាដើម ពពួកសម្ភារសេរ៉ាមិច

ដូចជាចានគោម ផើងរុក្ខជាតិ ជាដើម ពពួកកែវកញ្ចក់ ដូចជាកែវទឹក កញ្ចក់ អំពូលមូល ជាដើម

ពពួកប្លាស្ទិច ដូចជាច្រាសដុសធ្មេញ ឡាបូ ជាដើម

ថ្ងៃចោលបាន…ថ្ងៃ “សំរាមដុតមិនបាននិងសំរាមកែច្នៃ” (1ដងក្នុងមួយខែ)

វិធីចោល…សូមដាក់វាចូលក្នុង “ថង់ប្រមូលដែលគេកំណត់” ហើយចោលវានៅ

ថ្ងៃ “សំរាមដុតមិនបាននិងសំរាមកែច្នៃ” នៅកន្លែងចោលសំរាមដែលត្រូវបានកំណត់

អ្វីដែលត្រូវប្រុងប្រយ័ត្ននៅពេលចោល៖

- ចំពោះរបស់គ្រោះថ្នាក់ ដូចជាកែវកញ្ចក់ដែលបែក ឬកន្ត្រៃជាដើម សូមខ្ចប់វាដោយក្រដាសជាដើម
- សូមចងមាត់ថង់ ដើម្បីកុំឲ្យសំរាមខាងក្នុងចេញមកខាងក្រៅ
- សូមកុំដាក់ “សំរាមដុតបាន” និង “សំរាមដុតមិនបាន” ចូលក្នុងថង់តែមួយឲ្យសោះ





## ○ សំរាមកែច្នៃ (ពពួកដបកែវ)

ថ្ងៃចោលបាន…ថ្ងៃ “សំរាមដុតមិនបាននិងសំរាមកែច្នៃ” (1ដងក្នុងមួយខែ)

វិធីចោល…សូមញែកវាជា4ប្រភេទ គឺ “ដបកែវពណ៌ថ្លា” “ដបកែវថ្លា”

“ដបកែវពណ៌ផ្សេងទៀត” “ដបកែវប្រើឡើងវិញ” ហើយដាក់ចូលក្នុង

ប្រដាប់ដាក់ឯកទេសដោយបែងចែកទៅតាមប្រភេទដបកែវនោះ

អ្វីដែលត្រូវប្រុងប្រយ័ត្ននៅពេលចោល៖

- សូមដោះគម្របចេញ
- សូមកុំឲ្យមាននៅសល់អ្វីខាងក្នុងជាដាច់ខាត ហើយសូមលាងវាដោយប្រើទឹក
- សូមកុំដាក់កន្ទុយបារីជាដើម ចូលក្នុងដបកែវជាដាច់ខាត
- សូមកុំច្រកថង់ ដោយដាក់វាចូលក្នុងប្រដាប់ដាក់យកតែម្តង

※ ដបកែវប្រើឡើងវិញ…សំដៅលើដបកែវបៀយែរ ដបកែវស្រាជប៉ុន (ហៅថា អុិស្សូប៊ីន)

គេហៅវាថា ដបកែវប្រើឡើងវិញ ដោយសារគេអាចយកវាទៅប្រើឡើងវិញបានទាំងក្នុងសភាពអញ្ចឹង







## ○ សំរាមកែច្នៃ (ថ្មពិល ដែកកេស)

ថ្ងៃចោលបាន…ថ្ងៃ “សំរាមដុតមិនបាននិងសំរាមកែច្នៃ” (1ដងក្នុងមួយខែ)

វិធីចោល…សូមដាក់វាចូលក្នុងប្រដាប់ដាក់ឯកទេសដែលត្រូវបានលាបពណ៌លឿង

អ្វីដែលត្រូវប្រុងប្រយ័ត្ននៅពេលចោល៖

- សូមកុំច្រកថង់ ដោយដាក់វាចូលក្នុងប្រដាប់ដាក់យកតែម្តង
- ចំពោះផលិតផលដែលមានប្រើថ្មលីចូមសម្រាប់រក្សាថាមពល ដូចជាផារើបេងទូរសព្ទជាដើម សូមដោះយកតែថ្មចេញ

ហើយដាក់វាចូលក្នុងប្រដាប់ដាក់








## ○ សំរាមកែច្នៃ (ពពួកកំប៉ុង)

ថ្ងៃចោលបាន…ថ្ងៃ “សំរាមដុតមិនបាននិងសំរាមកែច្នៃ” (1ដងក្នុងមួយខែ)

វិធីចោល…សូមដាក់វាចូលក្នុងកន្ត្រកឯកទេសសម្រាប់ពពួកកំប៉ុង

អ្វីដែលត្រូវប្រុងប្រយ័ត្ននៅពេលចោល

・ សូមកុំឲ្យមាននៅសល់អ្វីខាងក្នុងជាដាច់ខាត ហើយសូមលាងវាដោយប្រើទឹក រួចចាំចោល

・ សូមកុំដាក់កន្ទុយបារីជាដើម ចូលក្នុងកំប៉ុងជាដាច់ខាត

・ មិនចាំបាច់ញែកកំប៉ុងអាលុយមីញ៉ូម និងកំប៉ុងដែក ទេ





## ○ សំរាមកែច្នៃ (ដបជ័រ)

ថ្ងៃចោលបាន…ថ្ងៃ “សំរាមដុតមិនបាននិងសំរាមកែច្នៃ” (1ដងក្នុងមួយខែ)

វិធីចោល…សូមដាក់វាចូលក្នុងកន្ត្រកឯកទេសសម្រាប់ដបជ័រ

អ្វីដែលត្រូវប្រុងប្រយ័ត្ននៅពេលចោល៖

・ សូមដោះគម្រប និងស្លាក ចេញ

※ ចំពោះគម្របនិងស្លាក ដែលបានដោះចេញ សូមចោលជាសំរាមកែច្នៃ(សម្ភារផ្ទុកនិងកញ្ចប់ប្លាស្ទិច)

・ សូមកុំឲ្យមាននៅសល់អ្វីខាងក្នុងជាដាច់ខាត ហើយសូមលាងវាដោយប្រើទឹក រួចចាំចោល






## ○ សំរាមកែច្នៃ (សម្ភារផ្ទុកនិងកញ្ចប់ប្លាស្ទិច)

របស់សំខាន់ៗ…ចានស្នោដាក់សាច់ឬត្រីជាដើម កញ្ចប់ដាក់ស៊ុត ថង់ដាក់នំឬនំប៉័ង ជាដើម កែវដាក់បង្អែមភូឌីងឬចាហួយជាដើម

ថ្ងៃចោលបាន…ថ្ងៃ “សំរាមដុតមិនបាននិងសំរាមកែច្នៃ” (1ដងក្នុងមួយខែ)

វិធីចោល…សូមដាក់វាចូលក្នុងថង់ថ្លា/ថ្លាពាក់កណ្ដាល ឬ ថង់ទិញអីវ៉ាន់

※ មិនចាំបាច់ដាក់ចូលក្នុង “ថង់ប្រមូលដែលគេកំណត់” ទេ

អ្វីដែលត្រូវប្រុងប្រយ័ត្ននៅពេលចោល៖

・ សូមលាងទឹក សំអាតអ្វីដែលប្រឡាក់ចេញ។ ចំពោះរបស់ណាដែលលាងប្រឡាក់មិនជ្រះ សូមចោលជាសំរាមដុតបាន។



## ○ សំរាមកែច្នៃ (ពពួកក្រដាស)

ថ្ងៃចោលបាន…ថ្ងៃ “សំរាមកែច្នៃ (ក្រដាស)” (1ដងក្នុងមួយខែ)

វិធីចោល…សូមញែកវាជា4ប្រភេទ គឺ “ក្រដាសទ្បាំង”

“ក្រដាសកាសែត/លិខិតផ្សព្វផ្សាយ” “ទស្សនាវដ្តី/ក្រដាសសំណល់”

“ដបក្រដាស” ហើយសូមប្រើខ្សែចងវាដោយបែងចែកទៅតាមប្រភេទក្រដាសនោះ

អ្វីដែលត្រូវប្រុងប្រយ័ត្ននៅពេលចោល៖

- សូមប្រុងប្រយ័ត្នព្រោះវាខុសពីថ្ងៃ “សំរាមដុតមិនបាននិងសំរាមកែច្នៃ”
- ចំពោះដបក្រដាស សូមលាងទឹក ហើយទុកឲ្យស្ងួត រួចកាត់វាបើក



## ○ សំរាមទំហំធំ

គឺជាសំរាមធំៗដែលច្រកក្នុង “ថង់ប្រមូលដែលគេកំណត់” មិនចូល

ហើយវាមានដូចជាកៅអី ទូ និងគ្រែជាដើម។

អ្នកមិនអាចចោលវានៅកន្លែងចោលសំរាមបានទេ។ បើចង់ចោលសំរាមប្រភេទនេះ សូមដាក់ពាក្យស្នើសុំទៅកាន់

ផ្នែកបរិស្ថានរស់នៅ របស់សាលាក្រុង។

អ្នកត្រូវបង់ថ្លៃសេវាសម្រាប់សំរាមនីមួយៗដែលអ្នកចោល។ (ត្រូវចំណាយប្រាក់)

នឹងមានការកំណត់ថ្ងៃខែ ដើម្បីឲ្យបុគ្គលិកប្រមូល ទៅផ្ទះរបស់អ្នកដើម្បីយកសំរាមនោះ។

※ នៅពេលគេប្រមូល អ្នកចាំបាច់ត្រូវមានវត្តមានជាដាច់ខាត។

អ្នកត្រូវបង់ថ្លៃសេវាជាមុន ហើយបុគ្គលិកប្រមូល នឹងពិនិត្យវិក្កយបត្រនៅពេលដែលគេទៅយកសំរាមនោះ។

※ អាចនឹងមានប្រភេទសំរាមខ្លះដែលក្រុងមិនអាចប្រមូលបាន។

កន្លែងដាក់ពាក្យស្នើសុំ៖ ផ្នែកបរិស្ថានរស់នៅ របស់សាលាក្រុងសាកាអ៊ិដេ (លេខទូរសព្ទ៖ 0877−46−4503)

